ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

ថ្មីៗនេះ មានព័ត៌មានមួយចំនួនបានលើកឡើងអំពីបញ្ហាតម្លៃស្វាយកែវរមៀតធ្លាក់ចុះនៅតំបន់មួយចំនួន ដែលធ្វើឱ្យអ្នកដាំដុះស្វាយមានការត្អូញត្អែរអំពីបញ្ហាតម្លៃស្វាយនេះ។ ជាទូទៅ ទាំងនៅក្នុងប្រទេសកម្ពុជា និងបណ្តាប្រទេសទាំងអស់នៅលើពិភពលោក តម្លៃផលិតផលកសិកម្ម រួមទាំងស្វាយផងដែរ មានការប្រែប្រួលឡើងចុះមិនទៀងទាត់តាមរដូវកាល និងអាស្រ័យលើទំហំនៃការផ្គត់ផ្គង់ និងតម្រូវការ។ ជាក់ស្តែង ដើមឆ្នាំនេះ ផ្លែស្វាយមានតម្លៃល្អប្រសើរ ប៉ុន្តែនាដើមខែកុម្ភៈនេះ តម្លៃផ្លែស្វាយមានការធ្លាក់ចុះ ដោយសារដល់រដូវកាលប្រមូលផលមានបរិមាណផ្លែស្វាយច្រើន។ ទន្ទឹមគ្នានេះដែរ ក៏មានអ្នកដាំស្វាយមួយចំនួនលក់បានតម្លៃទាប ដោយមូលហេតុថា ផ្លែស្វាយមិនទាន់មានគុណភាពល្អស្របតាមស្តង់ដារ ដូចជាមានទំហំតូច គ្មានសោភ័ណភាព និងមិនទាន់ស្របតាមលក្ខខណ្ឌតម្រូវនៃការបញ្ជាទិញរបស់ក្រុមហ៊ុន ស្របពេលនឹងរដូវកាលចូលឆ្នាំប្រពៃណីវៀតណាម និងចិន ធ្វើឱ្យពាណិជ្ជករផ្អាកការបញ្ជាទិញ។

ដើម្បីរក្សាបាននូវស្ថិរភាពតម្លៃសមស្រប និងមានទីផ្សារ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនដំណឹងសាជាថ្មីដល់អ្នកដាំដុះដំណាំស្វាយទាំងអស់ សូមរួសរាន់ធ្វើការចុះបញ្ជីកសិដ្ឋានដាំស្វាយសម្រាប់នាំចេញនៅអគ្គនាយកដ្ឋានកសិកម្ម ដើម្បីងាយស្រួលទទួលបានព័ត៌មាន និងសេវាបណ្តុះបណ្តាលបច្ចេកទេស ក្នុងការបង្កើនផលិតភាពនិងគុណភាពផ្លែស្វាយស្របតាមស្តង់ដារ ព្រមទាំងរៀបចំចងក្រងជាបណ្តុំអាជីវកម្មស្វាយ សម្រាប់ទំនាក់ទំនងជាមួយក្រុមហ៊ុនក្នុងនិងក្រៅស្រុក ចុះកិច្ចសន្យាប្រមូលទិញធ្វើការកែច្នៃនិងនាំចេញ។

ជាក់ស្តែង ក្នុងគោលដៅជំរុញការនាំផ្លែស្វាយទៅប្រទេសចិន អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្ញើជូនកសិដ្ឋានដែលបានចុះបញ្ជីជាកសិដ្ឋានសម្រាប់ការនាំចេញស្វាយទៅកាន់ប្រទេសចិនចំនួន ២៥កសិដ្ឋាន និងរោងចក្រប្រព្រឹត្តិកម្មសម្លាប់ពងរុយចោះផ្លែស្វាយដែលបានសាងសង់រួចរាល់ចំនួន ៣បន្ថែមទៀតទៅប្រទេសចិនដើម្បីពិនិត្យ និងវាយតម្លៃបន្ត។ សរុបមក កម្ពុជានឹងមានកសិដ្ឋានចំនួន៣០ និងរោងចក្រប្រព្រឹត្តិកម្មសម្លាប់ពងរុយចោះផ្លែស្វាយចំនួន០៤ ដែលប្រទេសចិន នឹងពិនិត្យសម្រេចអនុញ្ញាតឱ្យនាំចេញផ្លែស្វាយស្រស់ពីកម្ពុជាទៅកាន់ប្រទេសចិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបណ្តាញផ្សព្វផ្សាយព័ត៌មាន និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

Scanned with CamScanner

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320